ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

អគ្គនាយកដ្ឋានយោធសេវា

# សារលិខិតអបអរសាទរ

តាងនាមថ្នាក់ដឹកនាំនិងនាយទាហាន នាយទាហានរងទាំងអស់ នៅក្នុងអគ្គនាយកដ្ឋានយោធសេវា នៃក្រសួងការពារជាតិ មានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង និងសូមចូលរួមអបអរសាទរយ៉ាងស្មោះស្ម័គ្រជូនចំពោះ **ឯកឧត្តម ទៀ សីហា** ដែលត្រូវបាន **ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ត្រាស់បង្គាប់តែងតាំងជា "**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**" សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា។

តំណែងកំពូលនៃស្ថាប័នការពារជាតិ គឺពិតជាស័ក្តិសមបំផុតចំពោះ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ដែលប្រកបដោយឧត្តមគតិស្នេហាជាតិ មានចំណេះដឹងខ្ពស់ពោរពេញដោយសមត្ថភាព និងទេពកុសល ព្រមទាំងមានគុណធម៌ សីលធម៌ សុជីវធម៌ល្អ ដោយទទួលបានការកោតសរសើរ គោរពស្រឡាញ់ពីសំណាក់ថ្នាក់ដឹកនាំ នាយទាហា នាយទាហានរង និងពលទាហាន ទាំងអស់ក្នុងក្រសួងការពារជាតិ ដើម្បីប្រតិបត្តិបន្តទៅតាមមាគ៌ាដ៏ល្អត្រឹមត្រូវ និងជាញជ័យបំផុតរបស់ **សម្តេចពិជ័យសេនា ទៀ បាញ់** នៅក្នុងស្ថាប័នការពារជាតិទាំងបច្ចុប្បន្ន និងទៅអនាគត។

យើងខ្ញុំទាំងអស់គ្នាមានជំនឿយ៉ាងមុតមាំបំផុតលើសមត្ថភាព ភាពឈ្លាសវៃ ប៉ិនប្រសប់ សិល្បៈនៃការដឹកនាំ និងឆន្ទៈដ៏មុះមុតប្រកបដោយថាមពលរបស់ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** ក្នុងការដឹកនាំវិស័យការពារជាតិកម្ពុជាឆ្ពោះទៅរកវឌ្ឍនភាពបន្ថែមទៀត ព្រមទាំង បន្តការពាររដ្ឋធម្មនុញ្ញ ការពាររាជបល្ល័ង្ក ការពារឯករាជ្យ អធិបតេយ្យជាតិ បូរណភាពទឹកដី ការពារសន្តិភាព ស្ថិរភាពនយោបាយ លើកកម្ពស់កិត្យានុភាពជាតិ និងការអភិវឌ្ឍប្រទេសកាន់តែមានភាពរីកចម្រើនលើគ្រប់វិស័យ ដើម្បីវិបុលភាពសេចក្តីថ្លៃថ្នូរ និងសុភមង្គលរបស់ប្រជាជនកម្ពុជា។

ជាថ្មីម្តងទៀត ក្នុងឱកាសដ៏វិសេសវិសាលនេះ យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ ព្រមទាំង នាយទាហាន នាយ-ទាហានរង ក្នុងអគ្គនាយកដ្ឋានយោធសេវា នៃក្រសួងការពារជាតិ សូមជូនពរ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** និង **លោកជំទាវ** ព្រមទាំងបុត្រ ជួបប្រទះតែសេចក្តីសុខ សុភមង្គល ព្រមទាំងសមប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃពុធ ៧កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣